ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ........................................................

# សុន្ទរកថា
# ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងសិក្ខាសាលាសាធារណៈស្តីពី រូបិយវត្ថុ និងអធិបតេយ្យភាព
# ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ

នៅសណ្ឋាគារអាំងទែកុងទីណង់តាល់ ថ្ងៃទី៩ ខែតុលា ឆ្នាំ២០០៩

សូមគោរព :

- លោក Jean-Daniel Gardère អតីតទីប្រឹក្សាពាណិជ្ជកម្មនិងសេដ្ឋកិច្ចប្រចាំស្ថានទូតបារាំងនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី និងនាងកញ្ញា ជាទីមេត្រី

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយជាអនេក ដោយបានចូលរួមសិក្ខាសាលាសាធារណៈស្តីពីរូបិយវត្ថុ **និងអធិបតេយ្យភាព** ដែលរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា បន្ទាប់ពីយើងបានប្រារព្ធពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ (១០ តុលា ១៩៧៩-១០ តុលា ២០០៩) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីម្សិលមិញនេះ រួចមក ។

សិក្ខាសាលារបស់យើងនៅថ្ងៃនេះ ក៏ជាផ្នែកមួយដើម្បីចូលរួមអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើតធនាគារជាតិនៃកម្ពុជាឡើងវិញ និងដើម្បីបង្ហាញពីការវិវត្តរីកចម្រើននៃប្រព័ន្ធរូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុនៅកម្ពុជា តាំងពីបុរាណសម័យរហូតដល់បច្ចុប្បន្ននេះផងដែរ ។ ការកសាងប្រព័ន្ធធនាគារនៅកម្ពុជាឱ្យមានការរីកចម្រើនក្នុងរយៈពេល៣០ឆ្នាំ កន្លងមកនេះ ជារឿងរ៉ាវដ៏សែនវែងឆ្ងាយនៃប្រវត្តិសាស្ត្រ ដែលបានចំណាយពេលវេលា ធនធាន និងការតស៊ូព្យាយាមប្រកបដោយការលះបង់ ដើម្បីការពារ ស្តារ និងកសាងប្រព័ន្ធធនាគារនៅកម្ពុជាពីបាតដៃទទេ ឱ្យមានការរីកចម្រើនឡើងវិញរហូតដល់បច្ចុប្បន្ននេះ ។ ការរីកចម្រើនត្រូវប្រព្រឹត្តទៅតាមដំណាក់កាល ។ ដំណាក់កាលនេះ គឺជាប្រវត្តិនៃការវិវត្តរីកចម្រើន ។

**ឯកឧត្តម លោកជំទាវ លោក លោកស្រី និង នាងកញ្ញា ជាទីមេត្រី**

ខ្ញុំសូមឆ្លៀតឱកាសនេះ មុននឹងជម្រាបជូនពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ និងសារៈសំខាន់នៃរូបិយវត្ថុ និងហិរញ្ញវត្ថុ ខ្ញុំសូមជម្រាបជូនពីប្រវត្តិក្នុងការរៀបចំឯកសារនេះ ។


ប្រអប់សំបុត្រលេខ ២៥, ផ្លូវលេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

និយាយពីរឿងប្រវត្តិសាស្ត្រ ខ្ញុំជាអ្នកមានការចាប់អារម្មណ៍ផ្នែកប្រវត្តិសាស្ត្រខ្លាំងណាស់ ជាពិសេសប្រវត្តិនៃរូបិយវត្ថុនៅកម្ពុជាតែម្តង ។ តាមរយៈបទពិសោធន៍ និងការស្រាវជ្រាវ តាមរយៈការងារកន្លងមក ខ្ញុំសូមជម្រាបពីសារៈសំខាន់នៃប្រវត្តិសាស្ត្រ និងសារៈសំខាន់នៃប្រព័ន្ធរូបិយវត្ថុនិងហិរញ្ញវត្ថុនៅកម្ពុជា ដូចតទៅ :

**១/-សារៈសំខាន់នៃប្រវត្តិសាស្ត្រ :** ប្រវត្តិសាស្ត្រមានសារៈសំខាន់ណាស់ចំពោះប្រទេសជាតិ ខ្ញុំតែងតែធ្វើការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រជាប់ជាប្រចាំ ដើម្បីស្វែងយល់ពីអត្ថន័យនៃប្រវត្តិសាស្ត្រ និងរឿងរ៉ាវទាំងឡាយដែលកើតមានតាមសម័យកាលនីមួយៗ និងយកមកធ្វើជាមេរៀនសម្រាប់ចង្អុលទិស ក្នុងការអនុវត្តការងារបច្ចុប្បន្ន ។ តាមរយៈការសិក្សាស្រាវជ្រាវ ខ្ញុំអាចនិយាយបានថា ប្រវត្តិសាស្ត្រ គឺជាឃ្លាំងនៃបទពិសោធន៍ដ៏សម្បូរបែប ដែលកត់ត្រាពីរឿងរ៉ាវពីអតីតកាល ។ ប្រវត្តិសាស្ត្រអាចបង្រៀនយើងលើច្រើនទិដ្ឋភាព លើច្រើនមុខវិជ្ជា និងបង្ហាញពីបទពិសោធន៍ដ៏សម្បូរបែបនៃការគ្រប់គ្រង និងដឹកនាំ ។ បើសិនជាយើង មិនបានសិក្សាស្វែងយល់ពីប្រវត្តិសាស្ត្ររបស់ខ្លួនឱ្យបានច្បាស់លាស់ ដឹងពីចំណុចខ្លាំង ចំណុចខ្សោយ និងចំណុចខ្វះខាត គួរជៀសវាងនោះទេ នោះកំហុសឆ្គងដែលធ្លាប់កើតមាន វានឹងកើតឡើងវិញម្តងទៀត ។ ករណីនេះ យើងហៅជាភាសាអង់គ្លេសថា History repeats itself ។ នេះ គឺជាអត្ថន័យនៃការសិក្សាពីប្រវត្តិសាស្ត្រ ដែលយើងត្រូវតែចងចាំ ស្វែងយល់ និងជៀសវាង ។

**២/-សារៈសំខាន់នៃប្រព័ន្ធរូបិយវត្ថុ និងហិរញ្ញវត្ថុ :** លោក ហ្សង់ម៉ុយែរ បាននិយាយថា " រឿងរ៉ាវប្រវត្តិមនុស្សដែលកើតឡើងសំខាន់ជាងគេ គឺរឿងរ៉ាវពាក់ព័ន្ធនឹងរឿងហិរញ្ញវត្ថុនេះហើយ ឯរឿងអ្វីផ្សេងទៀតគឺវាកើតឡើងតាមក្រោយទេ " ។ នេះមានន័យថា ការរីកចម្រើននៃសង្គមមនុស្ស ផ្អែកលើកត្តាសំខាន់ពីរ *ទី១/*-ការធ្វើសង្គ្រាមដណ្តើមអំណាចរដ្ឋ ដើម្បីវាតទីយកទឹកដី និងដណ្តើមប្រជាជន ដើម្បីរៀបចំច្បាប់ទម្លាប់គ្រប់គ្រងទឹកដីនោះ គឺធ្វើបានត្រឹមតែដែនអធិបតេយ្យរបស់ខ្លួនប៉ុណ្ណោះ មិនមានវិសាលភាពលាតសន្ធឹងទេ ។ ប៉ុន្តែ *ទី២/*-ការធ្វើសង្គ្រាមពាណិជ្ជកម្មដណ្តើមទីផ្សារ គឺមានលក្ខណៈទូលំទូលាយ លើសពីដែនអធិបតេយ្យរបស់ខ្លួនដែលគេហៅថា ការធ្វើជាមហាអំណាចខាងសេដ្ឋកិច្ច ។ ការវាតទីផ្នែកសេដ្ឋកិច្ចនេះ ទើបមានវិសាលភាពទូលំទូលាយលើសពីទីតាំងភូមិសាស្ត្រដែលយើងបានកំណត់ និងមានឥទ្ធិពលយ៉ាងខ្លាំងទៅលើផ្នែកសង្គមកិច្ច វប្បធម៌ និងនយោបាយ ទាំងនៅក្នុងតំបន់ និងពិភពលោកទាំងមូល ។

ដូច្នេះ កត្តាជំរុញសង្គមមនុស្សឱ្យមានការរីកចម្រើន មិនបានធ្វើសង្គ្រាមដណ្តើមអំណាច ដើម្បីពង្រីកទឹកដីមួយផ្នែកទេ គឺការពង្រីកសកម្មភាពដោះដូរពាណិជ្ជកម្ម ទើបមានអត្ថន័យជ្រាលជ្រៅផង ។ សកម្មភាពដោះដូរពាណិជ្ជកម្ម ជួយជំរុញឱ្យសកម្មភាពសេដ្ឋកិច្ចរីកចម្រើន និងកែប្រែជីវភាពរស់នៅរបស់ប្រជាជនឱ្យកាន់តែប្រសើរឡើង ។ ការលាតសន្ធឹងនៃអំណាចទីផ្សារ តាមរយៈការធ្វើពាណិជ្ជកម្មនេះ ធ្វើឱ្យពិភពលោកយើងកាន់តែមានលក្ខណៈសមាហរណកម្មខ្លាំងឡើង ។ ក្នុងការធ្វើពាណិជ្ជកម្ម រាល់ការដោះដូរទំនិញ ត្រូវមានមធ្យោបាយដោះដូរដែលយើងហៅថា " **រូបិយវត្ថុ** " ។

នេះគឺជាតួនាទីរូបិយវត្ថុនៅក្នុងប្រវត្តិសាស្ត្រនៃមនុស្ស ។ ដោយសាររូបិយវត្ថុមានសារៈសំខាន់ នៅក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ទើបខ្ញុំមានបំណងចង់សិក្សាស្រាវជ្រាវពីប្រវត្តិរូបិយវត្ថុកម្ពុជា សម្រាប់សិស្ស និស្សិត សេដ្ឋវិទូ និងអ្នកសិក្សាស្រាវជ្រាវដើម្បីស្វែងយល់ ប៉ុន្តែយើងជួបការលំបាកយ៉ាងខ្លាំង ទាំងផ្នែកបច្ចេកទេស និងឯកសារ ដោយសារប្រទេសកម្ពុជា ឆ្លងកាត់ការបំផ្លិចបំផ្លាញដោយសារសង្គ្រាមកន្លងមក ។ បំណងនេះ បានចំណាយអស់រយៈពេលយ៉ាងយូរ ទើបខ្ញុំបានជួបលោក Michel Dabadie ជំនាញការមូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ប្រចាំនៅធនាគារជាតិនៃកម្ពុជា ។ តាមរយៈលោក Michel Dabadie បានណែនាំខ្ញុំឱ្យស្គាល់លោក **ហ្សង់ដានីញ៉ែល ហ្គារដែរ** (Jean-Daniel Gardère) អតីតទីប្រឹក្សាសេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុប្រទេសបារាំង ប្រចាំនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក អតីតប្រធានក្រុមប្រឹក្សាពាណិជ្ជកម្មក្រៅប្រទេសបារាំង និងជាអតីតទីប្រឹក្សាពាណិជ្ជកម្ម និងសេដ្ឋកិច្ចប្រចាំស្ថានទូតបារាំងនៅកម្ពុជា បានស្នើសុំឱ្យលោកសរសេរសៀវភៅមួយមានចំណងជើងថា " ***រូបិយវត្ថុ និងអធិបតេយ្យភាព*** " ។ ទីបំផុត ការខិតខំប្រឹងប្រែង បានកើតចេញជាលទ្ធផលឡើង ។ សៀវភៅនេះ អត្ថបទដើមជាភាសាបារាំង បច្ចុប្បន្នយើងកំពុងធ្វើការបកប្រែជាភាសាអង់គ្លេស និងខេមរភាសា សម្រាប់បម្រើឱ្យការសិក្សា ស្រាវជ្រាវរបស់សាធារណជនទូទៅបានស្វែងយល់ពីប្រវត្តិនៃរូបិយវត្ថុកម្ពុជា ។

ខ្លឹមសារក្នុងសៀវភៅនេះ បានលើកឡើងពីការបង្កើតរូបិយវត្ថុឱ្យប្រើប្រាស់ក្នុងសេដ្ឋកិច្ច ជារបកគំហើញមួយយ៉ាងអស្ចារ្យក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ ដែលបាននាំមកនូវការរីកចម្រើនទាំងសេដ្ឋកិច្ច និងសង្គម ។ រូបិយវត្ថុមិនត្រឹមតែបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការជួយសម្រួលការដោះដូរ ធ្វើជាខ្នាតវាស់តម្លៃ និងជាឧបករណ៍សន្សំ សម្រាប់ជំរុញសេដ្ឋកិច្ចឱ្យអភិវឌ្ឍបានឆាប់រហ័សប៉ុណ្ណោះទេ ប៉ុន្តែរូបិយវត្ថុក៏តំណាងឱ្យអត្តសញ្ញាណរបស់ជាតិ អធិបតេយ្យភាពជាតិ និងតំណាងឱ្យអំណាចនៃសេដ្ឋកិច្ចរបស់ប្រទេសផងដែរ ។ ជាងនេះទៅទៀត រូបិយវត្ថុក៏ជាវត្ថុតាងផ្នែកប្រវត្តិសាស្ត្រ ដែលអនុញ្ញាតឱ្យយើងដឹងពីការវិវត្តនៃសង្គម នយោបាយ និងសេដ្ឋកិច្ចរបស់ប្រទេសមួយ ក្នុងសម័យកាលនីមួយៗបាន ។

ចំពោះកម្ពុជាយើង ការរីកចម្រើនការប្រើប្រាស់រូបិយវត្ថុ មានសភាពយឺតយ៉ាវ បើប្រៀបធៀបនឹងប្រទេសនានាក្នុងតំបន់និងពិភពលោក ។ នេះក៏ដោយសារតែយើង មានសេដ្ឋកិច្ចពឹងផ្អែកជាសំខាន់តែទៅលើវិស័យកសិកម្ម ហើយប្រជាជនខ្មែរយើងមានវប្បធម៌ចែករំលែកឱ្យគ្នាទៅវិញទៅមក ឬដោះដូររវាងរបស់និងរបស់ជាជាងការដោះដូរដោយប្រើរូបិយវត្ថុ ។ គឺទើបតែនៅដើមសតវត្សរ៍ទី១៦ ក្នុងរាជ្យព្រះស្រីជេដ្ឋាធិរាមាធិបតីហៅ ស្តេចកន ប៉ុណ្ណោះ ដែលកម្ពុជាយើងបានបង្កើតរូបិយវត្ថុជាតិខ្មែរដំបូងបំផុតឈ្មោះថា *ប្រាក់ស្លឹង* ឱ្យចរាចរនៅក្នុងប្រទេស ។ ចំណែកឯនាសម័យមុននេះ កម្ពុជាយើងបានប្រើប្រាស់រូបិយវត្ថុបរទេសជាច្រើនប្រភេទ ហើយជាទូទៅ មិនមែនប្រើសម្រាប់ការដោះដូរនៅក្នុងប្រទេសនោះទេ គឺសម្រាប់តែការដោះដូរជាមួយបរទេស និងធ្វើជាគ្រឿងដង្វាយក្នុងជំនឿសាសនា ។ ការមិនប្រើប្រាស់រូបិយវត្ថុឱ្យមានវិសាលភាពនៅក្នុងសេដ្ឋកិច្ចនេះ បានក្លាយជាចំណុចខ្សោយរបស់ប្រទេស ហើយបណ្តាលឱ្យកម្ពុជានាសម័យនោះចុះឱនថយជាលំដាប់ ។

រហូតមកដល់សម័យអាណានិគមនិយមបារាំង អគ្គទេសាភិបាលឥណ្ឌូចិន បានសម្រេចបោះផ្សាយក្រដាសប្រាក់ឱ្យចរាចរនៅក្នុងប្រទេសទាំងបីនៃឥណ្ឌូចិនរួមមាន កម្ពុជា វៀតណាម និងឡាវ ។ រាល់ការសម្រេចចិត្តលើការគ្រប់គ្រងរូបិយវត្ថុ គឺស្ថិតនៅក្រោមបារាំង កម្ពុជាយើងមានរូបិយវត្ថុចរាចរក្នុងប្រទេសទូលំទូលាយក៏ពិតមែន ប៉ុន្តែយើងពុំមានអធិតេយ្យភាពនោះទេ ។ រូបិយវត្ថុត្រូវបានបារាំងយកធ្វើឈ្នាន់ ដើម្បីកេណ្ឌប្រមូលពន្ធពីប្រជាជនខ្មែរនៅគ្រប់ស្រទាប់វណ្ណៈ ។ នៅឆ្នាំ១៩៥៤ ក្រោយពីទទួលបានឯករាជ្យពីបារាំង កម្ពុជាបានបង្កើតធនាគារកណ្តាល និងរូបិយវត្ថុជាតិ ។ ប៉ុន្តែគួរឱ្យសោកស្តាយ របបប្រល័យពូជសាសន៍ ប៉ុល ពត បានលុបបំបាត់ការប្រើប្រាស់រូបិយវត្ថុ និងប្រព័ន្ធហិរញ្ញវត្ថុចោល ហើយបណ្តាលឱ្យសេដ្ឋកិច្ចជាតិលិចលង់ដល់ចំណុចសូន្យ ។

ដោយមើលឃើញអំពីសារៈសំខាន់របស់តួនាទីរូបិយវត្ថុនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ក្រោយថ្ងៃមហាជ័យជំនះ ៧ មករា ១៩៧៩ ក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម សម្តេចអគ្គមហាពញាចក្រី ហេង សំរិន និង សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ក្រុមប្រឹក្សាបដិវត្តប្រជាជនកម្ពុជា បានបង្កើតធនាគារជាតិនៃកម្ពុជា ហើយឈានទៅបោះរូបិយវត្ថុជាតិ "រៀល" ឡើងវិញនៅថ្ងៃទី២០ ខែមីនា ឆ្នាំ១៩៨០ ដើម្បីអភិវឌ្ឍជាតិមាតុភូមិ និងបង្ហាញពីអធិបតេយ្យភាពជាតិខ្មែរ នៅលើឆាកអន្តរជាតិ ។

ក្នុងរយៈពេល៣០ឆ្នាំ បន្ទាប់ពីរបបប្រល័យពូជសាសន៍ កម្ពុជាមានការវិវត្តរីកចម្រើនលើគ្រប់វិស័យ ក្នុងនោះវិស័យធនាគារ ក៏មានការរីកចម្រើនគួរឱ្យកត់សម្គាល់ផងដែរ ។ សមិទ្ធផលទាំងអស់នេះ គឺកើតឡើងដោយសារការខិតខំប្រឹងប្រែងរបស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាគ្រប់ជាន់ថ្នាក់ ក្នុងរយៈពេល៣០ឆ្នាំកន្លងមកនេះ ។ ឆ្លៀតពេលនេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរយ៉ាងខ្លាំង ចំពោះការខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ របស់មន្ត្រីបុគ្គលិកធនាគារជាតិនៃកម្ពុជាទាំងអស់ ដែលបានរួមចំណែកកសាងសមិទ្ធផលទាំងឡាយ ជូនធនាគារជាតិនៃកម្ពុជា និងប្រទេសជាតិកន្លងមក ពោលគឺបានចូលរួមចំណែកកសាងប្រព័ន្ធធនាគារនៅកម្ពុជា ឱ្យមានការរីកចម្រើន ទទួលបានជំនឿទុកចិត្តបន្ថែមពីសាធារណជនទូទៅ មានសុវត្ថិភាព មានសុខភាពរឹងមាំ ស្របតាមយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ឆ្នាំ២០០៦-២០១៥ របស់រាជរដ្ឋាភិបាល ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីមេត្រី

ដើម្បីឱ្យសិក្ខាសាលាយើង បានស្វែងយល់ពីប្រវត្តិរឿងរ៉ាវសំខាន់ៗ ទាក់ទងនឹងការចាប់ផ្តើម និងការវិវត្តការប្រើប្រាស់រូបិយវត្ថុនៅកម្ពុជា រហូតដល់ការបង្កើតរូបិយវត្ថុ និងធនាគារកណ្តាលជាតិនៅតាមសម័យកាលនីមួយៗ ចាប់តាំងពីសម័យហ្វូណនមកដល់បច្ចុប្បន្ន ខ្ញុំសូមអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងនាងកញ្ញា ទាំងអស់ ស្តាប់បទឧទ្ទេសនាម របស់ លោក ហ្សង់ដានីញ៉ែល ហ្គារខ្មែរ ជាអ្នកនិពន្ធ នឹងត្រូវធ្វើបទឧទ្ទេសនាមដោយផ្ទាល់ ។ សូមអញ្ជើញ លោក ហ្សង់ដានីញ៉ែល ហ្គារខ្មែរ។

**សូមអរគុណ**

# អ្នកឧទ្ទេសនាម

១. លោក Jean Daniel Gardere

ប្រវត្តិការងារ

-ឆ្នាំ១៩៦៩-១៩៧៦ : ទីប្រឹក្សាប្រចាំស្ថានទូតបារាំងនៅប្រទេសប្រេស៊ីល (១៩៦៩-១៩៧១) និងប្រទេសអ៊ីរ៉ង់ (១៩៧៣-១៩៧៦)

-ឆ្នាំ១៩៧៦-១៩៨៣ : ប្រធានគណៈកម្មាធិការបារាំង ផ្នែកវិភាគស្ថានភាពសេដ្ឋកិច្ចក្រៅប្រទេស នៅមជ្ឈមណ្ឌលបារាំងនៃពាណិជ្ជកម្មអន្តរជាតិ

-ឆ្នាំ១៩៨៤-១៩៨៧ : អគ្គនាយកមជ្ឈមណ្ឌលបារាំងនៃពាណិជ្ជកម្មអន្តរជាតិ

-ឆ្នាំ១៩៨៨-១៩៩៧ : ទីប្រឹក្សាសេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបារាំង ប្រចាំនៅទីក្រុងរ៉ូម ប្រទេសអ៊ីតាលី (១៩៨៨-១៩៩១) និងប្រចាំនៅទីក្រុងវ៉ាស៊ីនតោន សហរដ្ឋអាមេរិក (១៩៩២-១៩៩៧)

-ឆ្នាំ១៩៩៨-២០០៣ : អគ្គនាយកមជ្ឈមណ្ឌលបារាំងនៃពាណិជ្ជកម្មអន្តរជាតិ

-ឆ្នាំ២០០៣-២០០៥ : ទីប្រឹក្សាសេដ្ឋកិច្ចនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបារាំង សម្រាប់ប្រទេសទាំង៣នៃ Benelux នៅទីក្រុងប្រ៊ុចសែល

-ឆ្នាំ២០០៥-២០០៧ : ទីប្រឹក្សាសេដ្ឋកិច្ច និងពាណិជ្ជកម្ម នៅកម្ពុជា និងឡាវ ។

ប្រវត្តិនៃការសិក្សា

-ឆ្នាំ១៩៦២ : បរិញ្ញាបត្រប្រវត្តិ និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Paris sorbonne

-ឆ្នាំ១៩៦៣ : បរិញ្ញាបត្រច្បាប់ និងសេដ្ឋកិច្ច នៅសាកលវិទ្យាល័យ Paris Assas

-ឆ្នាំ១៩៦៣ : សញ្ញាបត្រពីវិទ្យាស្ថានសិក្សានយោបាយនៃទីក្រុងប៉ារីស

-ឆ្នាំ១៩៦៨ : សញ្ញាបត្រភូមិន្ទរដ្ឋបាល ប្រទេសបារាំង

២. ឯកឧត្តម ស៊ុំ សន្និសិទ្ធ បច្ចុប្បន្ន ជាអគ្គលេខាធិការធនាគារជាតិនៃកម្ពុជា

ប្រវត្តិការងារ

- មុនពេលមកបំរើការងារនៅធនាគារជាតិនៃកម្ពុជា ធ្លាប់ធ្វើជាអគ្គនាយកនៃក្រសួងផែនការ
- ពីឆ្នាំ១៩៩៨ ដល់បច្ចុប្បន្ន ជាអគ្គលេខាធិការ ធនាគារជាតិនៃកម្ពុជា ។

ប្រវត្តិនៃការសិក្សា

-ឆ្នាំ១៩៨៦ : សញ្ញាបត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ច ពីប្រទេសអាហ្សែបៃហ្សង់ (អតីតសហភាពសូវៀត)

-ឆ្នាំ១៩៩៧ : សញ្ញាបត្រអនុបណ្ឌិតផ្នែកសេដ្ឋកិច្ចហិរញ្ញវត្ថុ ពីប្រទេសអង់គ្លេស

-ឆ្នាំ២០០៣ : សញ្ញាបត្របណ្ឌិតផ្នែកសេដ្ឋកិច្ច ពីវិទ្យាស្ថានស្រាវជ្រាវសង្គមកិច្ច និងនយោបាយនៃបណ្ឌិតសភាវិទ្យាសាស្ត្ររុស្ស៊ី ប្រទេសរុស្ស៊ី ។